គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
**Committee for Free and Fair Elections in Cambodia**
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

# <u>សេចក្ដីជូនដំណឹង</u>

**គណៈកម្មាធិការ ខុមហ្វ្រែល** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី នាងកញ្ញា ជាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ និងអន្តរជាតិព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា គណៈកម្មាធិការខុមហ្វ្រែលនឹងរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី **"ការផ្ដល់អំណាចដល់ស្ត្រីក្នុងវិស័យនយោបាយ"** និង **"ស្ត្រីអាចធ្វើបាន"** ចំនួន០៣ វគ្គដល់*បេក្ខនារីឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិទី៣* ក្នុងខេត្តគោលដៅចំនួន០៣។

វគ្គបណ្ដុះបណ្ដាលនេះមានគោលបំណង ៖

១) បង្កើនសមត្ថភាពបេក្ខជនឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី អំពីរបៀបបង្កើតកម្មវិធីនយោបាយដោយផ្អែកលើសមភាពយេនឌ័រ ការតស៊ូមតិ និងសារៈសំខាន់នៃក្របខណ្ឌសិទ្ធិស្ត្រីជាសិទ្ធិមនុស្សដើម្បីកសាងគណនេយ្យភាពសង្គម និងអភិបាលកិច្ច ផែនការយុទ្ធសាស្ត្រសម្រាប់ការបោះឆ្នោត យុទ្ធនាការឃោសនាបោះឆ្នោតដោយជោគជ័យ ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ (ចំនុចសំខាន់ៗនៃច្បាប់បោះឆ្នោត នីតិវិធី និងបទបញ្ជារបស់ **គ ជ ប** របៀបដោះស្រាយជាមួយបច្ចេកទេសគ្រប់សង្កត់។

២) បង្កើនភាពអង់អាចក្លាហានដល់បេក្ខជនជាស្ត្រីក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

សេចក្ដីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញាតំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

### ទីកន្លែង និងកាលបរិច្ឆេទវគ្គបណ្ដុះបណ្ដាល

| ល រ | ខេត្ត | ស្រុក/ទីកន្លែង | កាលបរិច្ឆេទ | អ្នកទំនាក់ទំនង | លេខទូរសព្ទ័ |
|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | សាលាបឋមសិក្សាជ្រៃបាក់ ស្រុករលាប្អៀរ | ២០-២២/៤/២០១២ | លោក លាប ប៊ុនលាង | ០១២ ៣៤២៤១៧ |
| ២ | តាកែវ | សាលប្រជុំសាលាស្រុកត្រាំកក់, ស្រុកត្រាំកក់ | ២៨-៣០/៤/២០១២ | លោកស្រី សេង សុន្ទរី | ០១២៨៩២ ៤៨៦ |
| ៣ | កំពង់ចាម | ការិយាល័យកិច្ចការនារីស្រុកកំពង់សៀម,ស្រុកកំពង់សៀម | ២៨-៣០/៤/២០១២ | លោក ញឹក សុភី | ០៧៦ ៨២៨ ៧៧៧១ |

*សូមរក្សាសិទ្ធិក្នុងកែប្រែក្នុងករណីចាំបាច់*

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ផ្នែកអប់រំ និងយេនឌ័រ-ខុមហ្វ្រែល ៖
លោកស្រី **សឺនគេត សិរីលក្ខណ៍** (**អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រ** / ទូរសព្ទ័ ៖ ០១៧-៤៩៤-០០៤)
លោកស្រី **លី ខេង** (**មន្ត្រីអប់រំ និងយេនឌ័រ** / ទូរសព្ទ័ ៖ ០១២-៧៦២-០០១)

<u>**ទីស្នាក់ការកណ្ដាល**</u> ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**<u>Central Office</u> : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org